អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# កីឡាមួយណា?

# Which Sport Is It?



Written by TukTuk

Illustrated by Hen Choven



« កាលពីយប់មិញ តើអ្នកបានមើលកីឡាស៊ីហ្គេមដែរឬទេ? » យ៉េកបានសួរទៅក្មេងៗ។
« ខ្ញុំបានឃើញគេលេងកីឡាមួយប្រភេទដែលខ្ញុំចូលចិត្ត។ ខ្ញុំដូចជាមិនចាំឈ្មោះវាជាភាសាខ្មែរទេ តែដឹងថា មានមនុស្សពីរនាក់វាយរបស់មួយទៅវិញទៅមក »។
មករានិយាយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »





ថាហើយ មកករាក៏បានរត់ទៅយកគ្រាប់សីមួយមក។ ក្មេងៗក៏បាននាំគ្នាទាត់វាទៅឆ្ងាយតាមដែលខ្លួនអាចធ្វើទៅបាន។ « មើលនែ៎! យើងអាចទាត់វាបានដល់ទៅ៣ម៉ែត្រឯណោះ! »





យ៉េកនិយាយ « មើលទៅសប្បាយណាស់ តែនេះមិនមែនជាកីឡាដែលខ្ញុំបាននិយាយមុនហ្នឹងទេ។ គេប្រើដៃ មិនមែនប្រើជើងនោះទេ »។
រតនានិយាយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »





ពួកគេត្រឡប់មកវិញជាមួយនឹងបាល់ទះមួយគ្រាប់ ហើយចាប់ផ្ដើមដក់បាល់នោះជាមួយគ្នា។
« មើលនែ៎! យើងអាចដក់បាល់ទៅវិញទៅមកបានជាង១០ដងឯណោះ! »





យ៉េកនិយាយ « មើលទៅសប្បាយណាស់ តែនេះមិនមែនជាកីឡាដែលខ្ញុំបាននិយាយមុនហ្នឹងទេ។ គេប្រើរ៉ាកែត មិនមែនប្រើដៃនោះទេ »។
រតនានិយាយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »





នាងក៏រត់ទៅយករ៉ាកែតវាយសីម្តង។ ក្មេងៗក៏ប្រើរ៉ាកែតនោះវាយសីជាមួយគ្នា។
« មើលនែ៎! ពួកយើងអាចវាយវាទៅវិញទៅមកបានដល់ទៅ៥ដង ដោយមិន
ឱ្យគ្រាប់សីធ្លាក់ដល់ដីនោះទេ »។





យ៉េកនិយាយ « មើលទៅសប្បាយណាស់ តែនេះមិនមែនជាកីឡាដែលខ្ញុំបាននិយាយមុនហ្នឹងទេ។ គេប្រើគ្រាប់តូចមួយ មិនមែនគ្រាប់សីនោះទេ »។
មករាក៏ឆ្លើយ « អូ! ខ្ញុំដឹងថា អ្នកកំពុងនិយាយពីអ្វីហើយ! »





ក្មេងៗក៏បានទៅយករ៉ាកែតវាយប៉េងប៉ុងនិងគ្រាប់ពណ៌ទឹកក្រូចតូចមួយមក។ « តែយើងមិនមានតុឬសំណាញ់នោះទេ » រតនានិយាយដោយទឹកមុខក្រៀមក្រំ។ មករានិយាយ « តែយើងនៅតែលេងបានអីចឹង! »
ហើយមករាក៏យករ៉ាកែតវាយប៉េងប៉ុងនោះឡើងលើ។
« មើលនែ៎! ខ្ញុំអាចត្រេះគ្រាប់ប៉េងប៉ុងបានដល់ទៅមួយនាទីដោយមិនភ្លាត់ស្នៀតឡើយ! »











យ៉េកនិយាយ « ពិតជាល្អណាស់! តែនិយាយរួម កីឡាហ្នឹងគេលេងដោយប្រើដៃ មិនមែនប្រើជើង គេប្រើរ៉ាកែត ប្រើបាល់ មិនមែនប្រើគ្រាប់សី ហើយប្រើសំណាញ់ មិនមែនប្រើតុនោះទេ »។

រតនានិយាយ « អូ! ខ្ញុំមិនដែលឮពីកីឡាបែបនេះសោះ »។









យ៉េកនិយាយ « អូ! ខ្ញុំចាំបានហើយ! គេហៅថា កីឡាវាយកូនបាល់ »។
មករាសួរ « តើវាជាផ្នែកមួយនៃកីឡាស៊ីហ្គេមដែរឬទេ? »
« ត្រូវហើយ! វាដូចគ្នានឹងកីឡាវាយសីនិងវាយប៉េងប៉ុងអ៊ីចឹង។
ខ្ញុំស្គាល់ទីលានវាយកូនបាល់មួយកន្លែង ហើយខ្ញុំក៏មានរ៉ាកែតនិងបាល់ផងដែរ
តើអ្នកចង់លេងទេ? »
ក្មេងទាំងពីរក៏ឆ្លើយ « ចង់លេង! ចង់លេង! »





ដូច្នេះ យ៉េកក៏បានបើករ៉ឺម៉កកង់បីដឹកពួកគេទៅទីលានវាយកូនបាល់។
មករានិយាយ « ខ្ញុំវាយបាល់មិនត្រូវសោះ! ពិតជាពិបាកណាស់ »។
« មិនអីទេ »។ យ៉េកក៏បន្ត « អ្នកអាចចាប់ផ្ដើមដោយបោះបាល់ឱ្យគ្នាទៅវិញទៅមក »។





ក្មេងទាំងពីរក៏បានធ្វើតាមពាក្យយ៉េកបានប្រាប់ ហើយក៏លេងបានល្អជាងមុន។ បន្តិចក្រោយមក ពួកគេអាចវាយបាល់ឆ្លងកាត់សំណាញ់ទៅវិញទៅមកបានយ៉ាងស្ទាត់ជំនាញ។





ក្រោយមក យ៉េកបានបើកទូរទស្សន៍មើលការប្រកួតកីឡាវាយកូនបាល់។ កីឡាករប្រទេសកម្ពុជាបានយកឈ្នះការប្រកួតនេះ ហើយពួកគេទាំងអស់គ្នាក៏បានស្រែកហូរ ជយោ...ជយោ...ជយោ...!





មករានិយាយ « ខ្ញុំចង់រៀនវាយកូនបាល់បន្តទៀត។ នៅពេលដែលខ្ញុំធំឡើង ខ្ញុំប្រហែលអាចចូលរួមប្រកួតនិងយកឈ្នះគេក្នុងកីឡាស៊ីហ្គេមដែរ! »៕








# កីឡាមួយណា?

អ្នកនិពន្ធ៖ TukTuk

អ្នកគំនូរ៖ ហ៊ិន ឆវិន

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ R4C

TUKTUK

Rotary

ADV